# ប្រសាសន៍ប្រាំបីចំណុច ដែលសន្តីតេរេសា (កុលកូថា) ណែនាំជីវិតរបស់យើង



**ទីមួយ៖** យើងធ្លាក់ទឹកចិត្ត នៅពេលដែលមនុស្សនៅជុំវិញយើង មានចិត្តលោភលន់ មានចិត្តចង្អៀតចង្អល់ មានចិត្តស្អប់ និងមើលងាយអ្នកតូចតាច។ ដូច្នេះ ដើម្បីមានទំនាក់ទំនងជាមួយនឹងបងប្អូន ឯទៀតៗ យើងត្រូវយកចិត្តទុកដាក់អំពីការលើកលែងទោសជានិច្ច។ នេះគឺជាមូលដ្ឋាននៃអ្វីៗទាំងអស់ នៅក្នុងទំនាក់ទំនងគឺការលើកលែងទោស។

**ទីពីរ៖** ប្រសិនបើយើងមានចិត្តល្អ មានចិត្តស្រឡាញ់ ជួនកាលណែនាំឲ្យអ្នកដទៃគិតថា គាត់ចិត្តល្អជាមួយខ្ញុំដោយសារគាត់មានគំនិតផ្សេង គាត់មានល្បិច គាត់អែបអបខ្ញុំ គាត់ផ្អែមជាមួយខ្ញុំ។ តែទោះបីជាយ៉ាងណាក៏ដោយ សូមឲ្យយើងបន្តមានចិត្តល្អ មានចិត្តស្រឡាញ់ដែលចេញមកពីដួងចិត្តរបស់យើងដ៏ពិតប្រាកដមែន។ ទោះបីជាគេខិតខំរិះគន់យើង យើងត្រូវតែបន្តការតស៊ូ មានតែចិត្តល្អ និងចិត្តស្រឡាញ់ ដែលអាចណែនាំឲ្យបន្តិចម្តងៗពិភពលោករបស់យើង និងជីវិតរបស់យើងក្លាយទៅជាពិភពថ្មីនិងជីវិតថ្មី។

**ទីបី៖** ប្រសិនបើយើងចាប់ផ្តើមជោគជ័យនៅក្នុងជីវិត! ទោះបីជាមាន មិត្តភក្តិមិនស្មោះ មានសត្រូវដែលគេចង់ឲ្យយើងបរាជ័យ ឲ្យយើងធ្លាក់ចុះក៏ដោយ។ ចូរយើងតស៊ូជានិច្ច ដើម្បីទទួលបានជោគជ័យរបស់យើង។

**ទីបួន៖** ប្រសិនបើយើងមានចិត្តស្មោះត្រង់ និងបើយើងចេះយកចិត្តទុកដាក់មែនទែន! យើងចាប់ផ្តើមមើលមនុស្សយ៉ាងច្រើនដែលគ្មានចិត្តស្មោះត្រង់ ដែលកុហកយើង ដែលនិយាយមិនល្អអំពីយើង។ ចូរ កុំឲ្យយើងធ្លាក់ទឹកចិត្ត ឱ្យយើងបន្តតស៊ូ ដោយមានចិត្តស្មោះត្រង់ ចំពោះបងប្អូនឯទៀតៗ មានចិត្តស្មោះចំពោះព្រះជាម្ចាស់ និងយកចិត្តទុកដាក់ចំពោះកិច្ចដែលយើងបំពេញ។

**ទីប្រាំ៖** ប្រសិនបើយើងបានចំណាយពេលរាប់ឆ្នាំកសាងសកម្មភាពថ្មី បង្កើតកម្មវិធីថ្មី និងបង្កើតអ្វីដែលពិសេស ហើយមានមនុស្សមកបំផ្លាញនូវអ្វីដែលយើងកំពុងធ្វើទាំងនោះចោលក្នុងមួយព្រិចភ្នែកក៏ដោយ។ ចូរយើងមានចិត្តតស៊ូ ដើម្បីឱ្យយើងបន្តបង្កើតសកម្មភាព និងកម្មវិធីទាំងនោះជានិច្ច។

**ទីប្រាំមួយ៖** ប្រសិនបើយើងជាមនុស្សម្នាក់ដែលពោរពេញដោយអំណរសប្បាយ នៅក្នុងខ្លួនមានភាពស្ងៀមស្ងាត់ និងប្រាជ្ញាញាណ មួយរយភាគរយ គឺនឹងមានមនុស្សច្រណែនជាមួយយើង។ មូលហេតុអ្វីគាត់សប្បាយ? មូលហេតុអ្វីគាត់មានភាពស្ងៀមស្ងាត់ និងឈ្លាសវៃ? ហើយគេចាប់ផ្តើមរកមធ្យោបាយដើម្បីឱ្យយើងបាត់អំណរសប្បាយ។ ចូរឲ្យយើងបន្តយកចិត្តទុកដាក់ ធ្វើជាមនុស្សដែលចេះប្រមូលអំណរសប្បាយ ដែលមកពីព្រះជាម្ចាស់ផ្ទាល់ ពីព្រោះមានតែព្រះជាម្ចាស់ដែលប្រទានអំណោយសប្បាយ។

**ទីប្រាំពីរ៖** ប្រសិនបើថ្ងៃនេះយើងធ្វើអំពើល្អច្រើន យើងដឹងថាថ្ងៃស្អែកគេភ្លេចអស់ហើយ គេភ្លេចអ្វីដែលយើងខិតខំកសាង។ អ្វីៗដែលយើងធ្វើ គេចង់ទាមទារថែមទៀតនិងថែមទៀត ជួយនេះតែប៉ុណ្ណឹងមិនគ្រប់គ្រាន់នោះទេ។ ប៉ុន្តែអ្វីសំខាន់ ចូរយើងយកចិត្តទុកដាក់ពីមួយថ្ងៃទៅមួយថ្ងៃ ធ្វើអំពើល្អឲ្យមែនទែន កុំឲ្យយើងធ្លាក់ទឹកចិត្ត ហើយយើងបន្តជួយអស់ពីសមត្ថភាពនៅក្នុងសេចក្តីស្រឡាញ់។

**ទីប្រាំបី៖** សរុបមកអ្វីៗទាំងអស់ដែលយើងធ្វើ យើងមិនធ្វើដើម្បីតែបងប្អូនឯទៀតៗតែប៉ុណ្ណោះនោះទេ គឺយើងប្រព្រឹត្តចំពោះព្រះជាម្ចាស់ អ្វីៗដែលកើតឡើងនៅក្នុងសេចក្តីស្រឡាញ់ និងធម៌មេត្តាករុណាទាំងអស់នោះ គឺរវាងខ្ញុំផ្ទាល់និងព្រះជាម្ចាស់។ ខ្ញុំមិនធ្វើដើម្បីអ្នកដទៃនោះទេ គឺខ្ញុំធ្វើសម្រាប់ព្រះជាម្ចាស់ ដោយដឹងថាព្រះជាម្ចាស់ទទួលស្គាល់ ដោយដឹងថាព្រះជាម្ចាស់ណែនាំឲ្យខ្ញុំទៅមុខ។

រៀបរៀងដោយ៖ លោកអភិបាល អូលីវីយេ ជ្មឺតហាស្មេ
អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ
ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២ ថ្ងៃរំឭកសន្តី តេរេសា នៃទីក្រុងកុលគូថា